ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនអំពី **កម្មវិធីប្រឡងសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៨ វគ្គផ្តាច់ព្រ័ត្រ** នៅថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ៥:០០នាទីល្ងាចតទៅ នៅសាលមហោស្រពកោះពេជ្រ ដោយមានការផ្សាយផ្ទាល់តាមកញ្ចក់ទូរទស្សន៍បាយ័ន។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញសាធារណជនចូលរួមទស្សនាឱ្យបានច្រើនកុះករ ដើម្បីបង្កើតឱកាសសប្បាយរីករាយ និងលើកកម្ពស់តម្លៃការងាររបស់បងប្អូនកម្មករ កម្មការិនី ដែលកំពុងបម្រើការងារនៅក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ក៏ដូចជាអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣២ **ទិវាពលកម្មអន្តរជាតិ ១ ឧសភា**។

កម្មវិធីនេះ សហការរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហភាពសហព័ន្ធយុវជនកម្ពុជា (សសយក) អគ្គនាយកដ្ឋានវិទ្យុនិងទូរទស្សន៍បាយ័ន និងអង្គការសហជីព និងដោយមានការចូលរួមឧបត្ថម្ភ ដោយក្រុមហ៊ុនភេសជ្ជៈខាវ៉ាបាវ, អ៊ីឈឺតាន់ ក្រុមហ៊ុនរថយន្ត សាំង យ៉ុង ព្រមទាំងបណ្តាក្រុមហ៊ុន ផ្សេងៗជាច្រើនទៀត។

ថ្ងៃច័ន្ទ ១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

077226670/093415263